**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៦៥២ ប្រក. កសក

# ប្រកាស
## ស្តីពី
## ការផ្ទេរធនធាន និងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលនៃខណ្ឌ ផ្នែក សង្កាត់ រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត

---

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខាប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ

-បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៦ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានជលផល ទៅជារដ្ឋបាលជលផល

-បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

-បានឃើញប្រកាសលេខ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ

-បានឃើញប្រកាសលេខ៣៨៦ ប្រក.កសក.ប ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពរដ្ឋបាលជលផល

-បានឃើញប្រកាសលេខ២២០ ប្រក.កសក.ប ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរកសិកម្មរាជធានី ខេត្ត

-បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្មរាជធានី ខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ ខណ្ឌរដ្ឋបាលជលផលឱ្យស្ថិតក្រោមមន្ទីរកសិកម្មរាជធានី ខេត្ត

-យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១.-**

ត្រូវបានផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ដែលកំពុងបម្រើការងារនៅតាមខណ្ឌ ផ្នែក សង្កាត់ រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ រាជធានី ខេត្ត។

បញ្ជីរាយនាមមន្ត្រីរដ្ឋបាលព្រៃឈើនិងរដ្ឋបាលជលផល ដែលត្រូវផ្ទេរដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ២.-**

ថវិកាបន្ទុកបុគ្គលិក ចំណាយសម្រាប់មន្ត្រីរាជការដែលត្រូវបានផ្ទេរនៅក្នុងប្រការ១ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងផ្ទេរឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ដើម្បីគ្រប់គ្រងនិងចាត់ចែងបន្ត។

**ប្រការ៣.-**

ត្រារបស់ខណ្ឌ ផ្នែក រដ្ឋបាលព្រៃឈើនិងរដ្ឋបាលជលផល ដែលកំពុងប្រើប្រាស់បច្ចុប្បន្ន ត្រូវទុកជានិរាករណ៍។ រាល់ការចេញលិខិតអនុញ្ញាតផ្សេងៗត្រូវចុះទិដ្ឋាការ និងប្រើប្រាស់ត្រារបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ។

**ប្រការ៤.-**

នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ នាយកដ្ឋានផែនការនិងស្ថិតិ និងនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវសហការជាមួយរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលក្នុងការរៀបចំផ្ទេរបន្តនូវធនធានហិរញ្ញវត្ថុផ្សេងៗទៀតក្រៅពីបន្ទុកបុគ្គលិក ឱ្យទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ដើម្បីមន្ទីរមានលទ្ធភាពគ្រប់គ្រងធនធានព្រៃឈើនិងធនធានជលផលប្រកបដោយនិរន្តរភាព។

**ប្រការ៥.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានអង្គភាពពាក់ព័ន្ធ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត និងសាមីខ្លួនក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

វេង សាខុន

**កន្លែងទទួល** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ